Obama'08

BarackObama.com

# បារ៉ាក់ អូបាម៉ា ចំពោះបញ្ហាជនជាតិអាមេរិកដើមកំណើតអាស៊ី និងអ្នកកោះប៉ាស៊ីហ្វិច (AAPI)

## បារ៉ាក់ អូបាម៉ា : សាវតាដ៏រឹងមាំនៃការគាំទ្រចំពោះ AAPIs

**ផ្តល់នូវការថែទាំសុខភាពជារួម :** មានប្រជាជនអាមេរិកដើមកំណើតអាស៊ីជិត ២,៤ លាននាក់ ដែលគ្មានការធានារ៉ាប់រងសុខភាព។ បារ៉ាក់ អូបាម៉ា មានការប្តេជ្ញាចិត្តក្នុងការចុះហត្ថលេខាលើលិខិតបទដ្ឋានគតិយុត្តនៅចុងអណ្តត្តិរបស់លោក ដើម្បីធានាថាប្រជាពលរដ្ឋអាមេរិកគ្រប់រូបទទួលបានសេវាថែរក្សាសុខភាពដែលមានតម្លៃសមរម្យ មានគុណភាព និងនៅគ្រប់ទិសទី។ ផែនការរបស់ អូបាម៉ា នឹងជួយសន្សំសំចៃប្រជាជនទូទៅរបស់អាមេរិករហូតដល់ ២.៥០០ ដុល្លារក្នុងមួយឆ្នាំ សម្រាប់ការចំណាយលើការថែរក្សាសុខភាព ដោយការធ្វើទំនើបកម្មចំពោះប្រព័ន្ធថែរក្សាសុខភាពរបស់អាមេរិក និងលើកស្ទួយការទប់ស្កាត់ជម្ងឺ និងពង្រឹងសុខភាពសាធារណៈ។

**បញ្ចប់ទម្រង់នៃការរើសអើងចំពោះជាតិសាសន៍ និងប្រយុទ្ធប្រឆាំងនឹងការរើសអើង :** អូបាម៉ា បានចំណាយពេលវេលាក្នុងអាជីពជាអ្នករៀបចំសហគមន៍ មេធាវីការពារសិទ្ធិពលរដ្ឋ និងជាអ្នកតស៊ូមតិដែលត្រូវបានបោះឆ្នោតឡើងដើម្បីតស៊ូក្នុងការបញ្ចប់គ្រប់ទម្រង់ទាំងអស់នៃការរើសអើង។ អូបាម៉ា បានអនុម័តច្បាប់មួយនៅក្នុងព្រឹទ្ធសភានៃរដ្ឋអ៊ីលីណ័យដើម្បីធ្វើការកំណត់ និងប្រឆាំងចំពោះទម្រង់នៃការរើសអើងចំពោះជាតិសាស្ត្រ។ លោកនឹងប្រើប្រាស់បទពិសោធន៍ជីវិតរបស់លោកដើម្បីអនុម័តគោលនយោបាយក៏មានអត្ថន័យដែលការពារចំពោះសិទ្ធរបស់ជនជាតិភាគតិច។

**កំណែទម្រង់អន្តោប្រវេសន៍ :** បារ៉ាក់ អូបាម៉ា គឺជាសម្លេងនាំមុខគេក្នុងការកែទម្រង់យ៉ាងគ្រប់ជ្រុងជ្រោយចំពោះប្រព័ន្ធអន្តោប្រវេសន៍របស់យើង ដោយការផ្តល់នូវមធ្យោបាយទទួលបានសញ្ជាតិចំពោះជនអន្តោប្រវេសន៍ដែលគ្មានឯកសារ ការធានាសុវត្ថិភាពចំពោះព្រំដែនរបស់យើង និងការកែតម្រូវបញ្ហាការិយាល័យធិបតេយ្យអន្តោប្រវេសន៍ដែលខូចខាត។ ក្នុងនាមជាប្រធានាធិបតេយ្យ លោកនឹងតស៊ូដើម្បីកំណែទម្រង់យ៉ាងគ្រប់ជ្រុងជ្រោយដែលផ្តល់អាទិភាពក្នុងការរក្សាឱ្យគ្រួសារបាននៅជាមួយគ្នា និងការធ្វើឱ្យកម្មវិធីទិដ្ឋការ H1-B កាន់តែប្រសើរឡើង។

**បណ្តាក់ទុនចំពោះការអប់រំ :** អូបាម៉ា នឹងកែទម្រង់ និងផ្តល់ថវិការយ៉ាងគ្រប់គ្រាន់ចំពោះកម្មវិធី **គ្មានកុមារណាម្នាក់ត្រូវបានបោះបង់** (No Child Left Behind) ។ លោកនឹងដាក់ឱ្យសាលាមានការទទួលខុសត្រូវចំពោះការបង្រៀនភាសាអង់គ្លេសដល់សិស្ស ហើយនឹងបន្តការតស៊ូរបស់លោកចំពោះការបង្កើន និងការកែទម្រង់ជំនួយហិរញ្ញវត្ថុចំពោះវិទ្យាល័យ ។

**បណ្តាក់ទុនចំពោះអាជីវកម្មធុនតូច :** AAPIs ជាម្ចាស់លើអាជីវកម្មធុនតូចជាង ១,១ ។ បារ៉ាក់ អូបាម៉ា នឹងគាំទ្រចំពោះកម្មវិធីសហព័ន្ធដែលបណ្តាក់ទុនចំពោះអាជីវកម្មដែលជាកម្មសិទ្ធិរបស់ជនជាតិភាគតិច ផ្តល់នូវជំនួយបច្ចេកទេសចំពោះម្ចាស់អាជីវកម្មធុនតូច និងកាត់បន្ថយការរើសអើងចំពោះកម្ចី ។

**សមធមិចំពោះអតីតយុទ្ធជនហ្វីលីពីន :** កងទ័ពហ្វីលីពីនប្រហែល ២៥០.០០០នាក់បានចូលរួមជាមួយកងទ័ពអាមេរិកក្នុងសង្គ្រាមលោកលើកទីពីរ ។ ក៏ប៉ុន្តែ ប្រទេសរបស់យើងមិនទាន់បានទទួលស្គាល់ចំពោះការលះបង់ដែលអតីតយុទ្ធជនទាំងនេះបានធ្វើឡើងចំពោះប្រទេសយើងឡើយ ។ បារ៉ាក់ អូបាម៉ា ជាអ្នកតស៊ូមតិដ៏រឹងមាំម្នាក់នៃច្បាប់សមធមិអតីតយុទ្ធជនហ្វីលីពីន ឆ្នាំ២០០៧ (the Filipino Veterans Equity Act of 2007) ដែលបំពេញសន្យារបស់អាមេរិកក្នុងការទទួលស្គាល់ និងគាំទ្រចំពោះអតីតយុទ្ធជនដ៏ហានក្លាទាំងនេះ ។